ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

លេខ ១៥៣ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការណែនាំអនុវត្តការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល ចំពោះសហគ្រាសបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92.Sangkat Wat Phnom . Khan Daun Penh. Phnom Penh. CAMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

# សម្រេច

## ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងណែនាំអនុវត្តការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល ដូចមានចែងក្នុងអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដើម្បីអភិវឌ្ឍវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ២.- គោលដៅ

ប្រកាសនេះ មានគោលដៅកំណត់ឱ្យបានច្បាស់លាស់នូវលក្ខខណ្ឌពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលលើកដំបូងជាសាធារណៈ ដើម្បីទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល ដូចមានចែងក្នុងអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ។

## ប្រការ ៣.- វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលលើកដំបូងជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៤.- លក្ខខណ្ឌ ដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល

សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលត្រូវបានកំណត់អំពីលក្ខខណ្ឌដូចខាងក្រោម÷

១. សហគ្រាសដែលបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទំហំលើសពី ២០ (ម្ភៃ) ភាគរយ នៃសិទ្ធិបោះឆ្នោត និង/ឬបោះផ្សាយមូលបត្របំណុលក្នុងទំហំលើសពី ២០ (ម្ភៃ) ភាគរយ នៃទ្រព្យសកម្មសរុប និងមានឥណប្រតិទានយ៉ាងតិច ៧ (ប្រាំពីរ) ឆ្នាំ នឹងទទួលបានការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូលចំនួន ៥០ (ហាសិប) ភាគរយ នៃពន្ធលើប្រាក់ចំណូលត្រូវបង់សម្រាប់រយៈពេល ៣ (បី) ឆ្នាំ នៅពេលដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ដោយអនុលោមតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ។

២. សហគ្រាសដែលបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទំហំ ២០ (ម្ភៃ) ភាគរយ ឬតិចជាង នៃសិទ្ធិបោះឆ្នោត និង/ឬបោះផ្សាយមូលបត្របំណុលក្នុងទំហំ ២០ (ម្ភៃ) ភាគរយ ឬតិចជាង នៃទ្រព្យសកម្មសរុប នឹងត្រូវទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលសម្រាប់រយៈពេល ៣ (បី) ឆ្នាំ តាមសមាមាត្រចុះដោយយក ២០,០០១ ភាគរយ ជាគោល (ដូចមានក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ) ដែលក្នុងនោះ÷

- ការបោះផ្សាយមូលបត្រកម្មសិទ្ធិ÷ ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលតាមសមាមាត្រ មិនឱ្យលើសពី ២០ (ម្ភៃ) ប៊ីលានរៀល។
- ការបោះផ្សាយមូលបត្របំណុល÷ ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលតាមសមាមាត្រ មិនឱ្យលើសពី ៨ (ប្រាំបី) ប៊ីលានរៀល។

**ប្រការ ៥.-  ការបំពេញកាតព្វកិច្ចសារពើពន្ធ**

សហគ្រាសដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ ត្រូវដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ និងបំពេញកាតព្វកិច្ចសារពើពន្ធដទៃទៀតឱ្យបានទៀងទាត់ ពុំនោះទេការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ ត្រូវបានដកហូត។

**ប្រការ ៦.-  ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយក នៃគណៈកម្មការមូលបត្រកម្ពុជា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាស និងស្ថាប័នពាក់ព័ន្ធនានា ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

ថ្ងៃសុក្រ ១៣ កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ [illegible] សហវ.ប្រក ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## តារាងសមាមាត្រក្នុងការផ្តល់ការលើកទឹកចិត្តពន្ធដារ

## ដោយយកទំហំនៃការបោះផ្សាយ ២០,០០១%* ជាគោល

| ល.រ. | ទំហំបោះផ្សាយ | សមាមាត្រ ភាគរយនៃការ លើកទឹកចិត្តទទួលបាន | ភាគរយនៃការ លើកទឹកចិត្តលើ ប្រាក់ពន្ធត្រូវបង់ ប្រចាំឆ្នាំ (ដូចក្នុងអនុក្រឹត្យ) | ល.រ. | ទំហំបោះផ្សាយ | សមាមាត្រ ភាគរយនៃការ លើកទឹកចិត្តទទួលបាន | ភាគរយនៃការ លើកទឹកចិត្តលើ ប្រាក់ពន្ធត្រូវបង់ ប្រចាំឆ្នាំ (ដូចក្នុងអនុក្រឹត្យ) |
|---|---|---|---|---|---|---|---|
| | A | B = A / 20.001% | C = B * 50% | | A | B = A / 20.001% | C = B * 50% |
| 1 | ចាប់ពី 20.001% | 100.000% | 50.000% | 21 | 10.500% | 52.497% | 26.249% |
| 2 | 20.000% | 99.995% | 49.9975% | 22 | 10.000% | 49.998% | 24.999% |
| 3 | 19.500% | 97.495% | 48.748% | 23 | 9.500% | 47.498% | 23.749% |
| 4 | 19.000% | 94.995% | 47.498% | 24 | 9.000% | 44.998% | 22.499% |
| 5 | 18.500% | 92.495% | 46.248% | 25 | 8.500% | 42.498% | 21.249% |
| 6 | 18.000% | 89.996% | 44.998% | 26 | 8.000% | 39.998% | 19.999% |
| 7 | 17.500% | 87.496% | 43.748% | 27 | 7.500% | 37.498% | 18.749% |
| 8 | 17.000% | 84.996% | 42.498% | 28 | 7.000% | 34.998% | 17.499% |
| 9 | 16.500% | 82.496% | 41.248% | 29 | 6.500% | 32.498% | 16.249% |
| 10 | 16.000% | 79.996% | 39.998% | 30 | 6.000% | 29.999% | 14.999% |
| 11 | 15.500% | 77.496% | 38.748% | 31 | 5.500% | 27.499% | 13.749% |
| 12 | 15.000% | 74.996% | 37.498% | 32 | 5.000% | 24.999% | 12.499% |
| 13 | 14.500% | 72.496% | 36.248% | 33 | 4.500% | 22.499% | 11.249% |
| 14 | 14.000% | 69.997% | 34.998% | 34 | 4.000% | 19.999% | 10.000% |
| 15 | 13.500% | 67.497% | 33.748% | 35 | 3.500% | 17.499% | 8.750% |
| 16 | 13.000% | 64.997% | 32.498% | 36 | 3.000% | 14.999% | 7.500% |
| 17 | 12.500% | 62.497% | 31.248% | 37 | 2.500% | 12.499% | 6.250% |
| 18 | 12.000% | 59.997% | 29.999% | 38 | 2.000% | 10.000% | 5.000% |
| 19 | 11.500% | 57.497% | 28.749% | 39 | 1.500% | 7.500% | 3.750% |
| 20 | 11.000% | 54.997% | 27.499% | 40 | 1.000% | 5.000% | 2.500% |

សម្គាល់÷

$$\text{ភាគរយនៃការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល} = \frac{\text{ទំហំបោះផ្សាយធៀបនឹងសិទ្ធិបោះឆ្នោតសរុប ឬទ្រព្យសកម្មសរុប}}{\text{ទំហំបោះផ្សាយគោល (20.001\%)}} \times 50\%$$

* សម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ÷ ទំហំបោះផ្សាយត្រូវធៀបនឹងចំនួនមូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតសរុប។

* សម្រាប់ការបោះផ្សាយលក់មូលបត្របំណុល÷ ទំហំបោះផ្សាយត្រូវធៀបនឹងទ្រព្យសកម្មសរុប។